# ចំណាត់ការលើ
# បណ្តឹងតវ៉ារបស់តតិយជន

រៀបរៀងដោយ៖ លោក MAEDA YUTA
ចៅក្រមនៃប្រទេសជប៉ុន
ប្រែសម្រួលដោយ៖ លោក **ឈឿន គុយអេង**

២៧.០៥.២០១៨

PART OF YOUR RESOLUTION

រួមគ្នាបង្កើនចំណេះដឹង ដើម្បីទាំងអស់គ្នា

# បណ្តឹងតវ៉ារបស់តតិយជន គឺជា

- បណ្តឹងរបស់តតិយជនដែលមានកម្មសិទ្ធិ ជាអាទិ៍ ចំពោះវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ទាមទារកុំឱ្យអនុញ្ញាតការអនុវត្តទៅលើទ្រព្យសម្បត្តិជាក់លាក់ ដោយផ្អែកលើលិខិតអនុវត្តជាក់លាក់ ចំពោះម្ចាស់បំណុលនៃការអនុវត្ត( CCP365.I )

- បណ្តឹងតវ៉ារបស់តតិយជន គឺធ្វើឡើងតាមនីតិវិធីរដ្ឋប្បវេណីទូទៅ។ ដូចនេះ ការវិនិច្ឆ័យលើបណ្តឹងនេះត្រូវយកក្រមនីតិវិធីរដ្ឋប្បវេណីគន្ថីទី២ និងគន្ថីទី៣ មកអនុវត្ត ហើយនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់ និងការទាញហេតុផលផ្ទាល់មាត់ គឺត្រូវតែមានជាចាំបាច់ ( CCP 80.I , 113 )

- បណ្តឹងតវ៉ានេះអាចដាក់បានមិនត្រឹមតែករណីការអនុវត្តដោយបង្ខំក្នុងន័យចង្អៀតនោះទេ ការអនុវត្តសិទ្ធិប្រាតិភោគ និង ការអនុវត្តរក្សាការពារក៏អាចដាក់បានដែរ។

# សមត្ថកិច្ច

- មានបញ្ញត្តិក្នុងក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា៣៦៥ កថាខណ្ឌទី២។
- ក្នុងករណីតុលាការអនុវត្តជាស្ថាប័នដែលត្រូវអនុវត្តដោយបង្ខំ
  →តុលាការអនុវត្ត
- ក្នុងករណីអាជ្ញាសាលាជាស្ថាប័នដែលត្រូវអនុវត្តដោយបង្ខំ
  →សាលាដំបូងដែលអាជ្ញាសាលានោះស្ថិតនៅ

※ នៅក្នុងប្រទេសជប៉ុន ប្រសិនបើសាលាឧទ្ធរណ៍ជាតុលាការអនុវត្ត សាលាដំបូងមានសិទ្ធិជាសមត្ថកិច្ចជម្រះក្តីលើកទី១ចំពោះការតវ៉ា របស់តតិយជន ការអនុវត្តបែបនេះធ្វើឡើងដោយពិចារណាអំពីផលប្រយោជន៍នៃការទទួលបានការជម្រះក្តីគ្រប់ថ្នាក់របស់ភាគី និងការទទួលបន្ទុកតាមមុខងាររបស់តុលាការ។

# ពេលដាក់ពាក្យបណ្តឹង

- ជាគោលការណ៍ គឺនៅក្រោយពេលចាប់ផ្តើមការអនុវត្តដោយបង្ខំ
  ∵ កម្មវត្ថុនៃការអនុវត្តមិនអាចកំណត់បានទេ បើសិនជាមិនមែននៅក្រោយពេលចាប់ផ្តើមអនុវត្ត

- ក្នុងករណីកម្មវត្ថុនៃការអនុវត្តអាចកំណត់បាននៅដំណាក់កាលលិខិតអនុវត្ត (ការអនុវត្តដោយបង្ខំនៃសិទ្ធិទាមទារឱ្យប្រគល់ ឬការប្រគល់វត្ថុជាក់លាក់) យើងអាចដាក់បណ្តឹងតវ៉ារបស់តតិយជនបាន នៅមុនពេលចាប់ផ្តើមការអនុវត្តដោយបង្ខំ។

- បណ្តឹងតវ៉ារបស់តតិយជនមិនអាចដាក់បាន ក្រោយពេលបញ្ចប់នៃការអនុវត្តដោយបង្ខំទេ។

# ការរួមបញ្ចូលបណ្តឹង

- បណ្តឹងតវ៉ារបស់តតិយជនជាបណ្តឹងរដ្ឋប្បវេណី ហេតុដូច្នេះ បណ្តឹងនេះអាចរួមបញ្ចូលជាមួយបណ្តឹងផ្សេងបាន។

- ប្រភេទនៃបណ្តឹងដែលមានលក្ខណៈសមស្របដើម្បីបញ្ចូលបាន មានដូចជា បណ្តឹងទាមទារឱ្យបញ្ជាក់អំពីកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុអនុវត្តដែលតតិយជនបានដាក់ចំពោះម្ចាស់បំណុលនៃការអនុវត្ត និង កូនបំណុលនៃការអនុវត្ត ឬ ការទាមទារសំណងការខូចខាត (អំពើអនីត្យានុកូល) ដោយផ្អែកលើការអនុវត្តដោយបង្ខំដែលមិនត្រឹមត្រូវដែលតតិយជនបានដាក់ចំពោះម្ចាស់បំណុលនៃការអនុវត្ត ជាអាទិ៍។

# ការផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹង

- បណ្តឹងតវ៉ារបស់តតិយជនជាបណ្តឹងរដ្ឋប្បវេណី ហេតុនេះ យើងអាចផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹងបាន ប្រសិនបើលក្ខខណ្ឌបានបំពេញ (CCP84.I)។

- ឧទាហរណ៍ចំពោះការផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹង យើងអាចពិចារណាបានក្នុងករណីដែលការអនុវត្តបានបញ្ចប់នៅពេលដែលបណ្តឹងតវ៉ារបស់តតិយជនកំពុងតែដំណើរការ នោះបណ្តឹងតវ៉ារបស់តតិយជននឹងក្លាយជាខុសច្បាប់ ហេតុនេះ ដើមចោទអាចដាក់ពាក្យសុំផ្លាស់ប្តូរកម្មវត្ថុបណ្តឹងទៅជាការទាមទារសំណងការខូចខាត បើសិនជាដើមចោទទទួលរងការខូចខាតដោយសារតែការអនុវត្តនោះ។

# ការវិនិច្ឆ័យបណ្តឹងតវ៉ារបស់តតិយជន

• បណ្តឹងតវ៉ារបស់តតិយជននឹងត្រូវបានទទួលស្គាល់ ក្នុងករណីដែល①តតិយជន (ដើមចោទ) មានសិទ្ធិដាក់លាក់ចំពោះវត្ថុដែលជាកម្មវត្ថុនៃការអនុវត្ត ហើយ②សិទ្ធិនោះត្រូវបានបំពាន និង③តតិយជននោះមិនមានមូលហេតុនឹងត្រូវទទួលយកការអនុវត្តដែលបំពាននោះ។

⇒ តតិយជន (ដើមចោទ) ត្រូវតែអះអាងអំពីសិទ្ធិលើកម្មវត្ថុនៃការអនុវត្ត អំពីការទទួលរងការបំពានដោយខុសច្បាប់សារធាតុនៅក្នុងទំនាក់ទំនងជាមួយម្ចាស់បំណុលនៃការអនុវត្ត (ចុងចម្លើយ)។

# ការវិនិច្ឆ័យបណ្ដឹងតវ៉ារបស់តតិយជន

- ចំណុចសំខាន់ដើម្បីសម្រេចថាទទួលស្គាល់ ឬ មិនទទួលស្គាល់បណ្ដឹងតវ៉ារបស់តតិយជន (= ហេតុនៃការតវ៉ាត្រូវបានទទួលស្គាល់ឬទេ) មាន ២ ចំណុចដូចខាងក្រោម៖

① តើដើមចោទមានសិទ្ធិដែលអាចតតាំងជាមួយម្ចាស់បំណុលនៃការអនុវត្ត (= សិទ្ធិដែលអាចរាំងស្ទះការធ្វើអនុប្បទាន ឬ ប្រគល់វត្ថុដែលជាកម្មវត្ថុ) ចំពោះវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដែរឬទេ?

② តើសិទ្ធិខាងលើរបស់ដើមចោទត្រូវបានបំពានដោយការអនុវត្តដែរឬទេ?

# អង្គហេតុចម្បង

- អង្គហេតុចម្បងនៃការតវ៉ារបស់តតិយជន

(1) អង្គហេតុដែលជាមូលហេតុនៃការទាមទារ

① ការចាប់ផ្ដើមនីតិវិធីអនុវត្តជាក់ស្ដែង(ករណីទូទៅ)

② អង្គហេតុដែលជាមូលហេតុនៃការកកើតសិទ្ធិដែលរាំងស្ទះការធ្វើអនុប្បទាន ឬ ប្រគល់វត្ថុដែលជាកម្មវត្ថុ

(2) ការតវ៉ា

③ ការបញ្ចប់នីតិវិធីអនុវត្ត

④ អង្គហេតុរំលត់សិទ្ធិ ឬ ឧបសគ្គនៃការកកើតសិទ្ធិដែលរាំងស្ទះការធ្វើអនុប្បទាន ឬ ប្រគល់របស់ដើមចោទ

# ហេតុនៃការតថា

1. កម្មសិទ្ធិ

បុគ្គលដែលមានកម្មសិទ្ធិចំពោះវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំផ្អែកតាមលិខិតអនុវត្តចំពោះអ្នកដទៃ អាចដាក់បណ្តឹងតវ៉ារបស់តតិយជន និងដកចេញការអនុវត្តទៅលើកម្មវត្ថុខាងលើ។

※ លើកលែងតែករណីកម្មសិទ្ធិនោះអាចតតាំងចំពោះម្ចាស់បំណុល (ចុងចម្លើយ) បាន។ (អនុវត្តដូចគ្នាចំពោះសិទ្ធិប្រត្យក្សផ្សេងទៀត)

# ហេតុនៃការតវ៉ា

1. កម្មសិទ្ធិ

ជាធម្មតា បើសិនជាការអនុវត្តដោយបង្ខំនោះ មិនធ្វើឱ្យបំពានដល់កម្មសិទ្ធិទេ បណ្ដឹងតវ៉ារបស់តតិយជនដែលធ្វើឡើងដោយកម្មសិទ្ធិករមិនត្រូវបានទទួលស្គាល់ទេ។

២. ទោះបីជា C ដែលជាម្ចាស់បំណុលរបស់ B បានអនុវត្តដោយបង្ខំទាមទារឱ្យប្រគល់ដី L ដែល A មានកម្មសិទ្ធិ ហើយ B កំពុងតែកាន់កាប់ក៏ដោយ ក៏ការផ្ទេរការកាន់កាប់ដី L ពី B ទៅ C មិនធ្វើឱ្យប៉ះពាល់ដល់កម្មសិទ្ធិរបស់ A នោះទេ។

# ហេតុនៃការតវ៉ា

១. កម្មសិទ្ធិ

ចុះបើនៅក្នុងទំនាក់ទំនងអវិភាគ?

⇒ នៅពេលតតិយជនបំពានវត្ថុអវិភាគ កម្មសិទ្ធិករអវិភាគម្នាក់ៗអាចទាមទារឱ្យដកចេញការបំពានដោយឯកឯងចំពោះវត្ថុអវិភាគទាំងមូលបាន ដោយផ្អែកលើចំណែកសិទ្ធិអវិភាគ (CC 206) ហេតុនេះ កម្មសិទ្ធិករអវិភាគអាចដាក់បណ្តឹងតវ៉ារបស់តតិយជនសម្រាប់វត្ថុអវិភាគទាំងមូលដោយឯកឯងបាន។

※ ប៉ុន្តែ ក្នុងករណីដែលក្នុងចំណោមម្ចាស់សិទ្ធិអវិភាគនោះមានបុគ្គលខ្លះជាកូនបំណុលនៃការអនុវត្ត នោះការអនុវត្តលក់ដោយបង្ខំលើចំណែករបស់កូនបំណុលនៃការអនុវត្តនោះគឺស្របច្បាប់ ហើយបណ្តឹងតវ៉ារបស់តតិយជនមិនអាចដកចេញការអនុវត្តលើចំណែកនោះទេ។

# ហេតុនៃការតវ៉ា

2. សិទ្ធិកាន់កាប់

អ្នកមានសិទ្ធិកាន់កាប់ដោយប្រយោលក្តី ឬ ដោយចំពោះក្តី អាចដាក់បណ្តឹងតវ៉ារបស់តតិយជន បើសិនជាសិទ្ធិកាន់កាប់ត្រូវបានបំពានដោយការអនុវត្តដោយបង្ខំផ្អែកតាមលិខិតអនុវត្តចំពោះអ្នកដទៃ។

ឧ. កម្មសិទ្ធិករ C បានអនុវត្តដោយបង្ខំផ្អែកតាមលិខិតអនុវត្តចំពោះកម្មសិទ្ធិករដើម A ទាមទារឱ្យប្រគល់ដី L ដែល B កាន់កាប់ ។

# ហេតុនៃការតថ៉ា

3. សិទ្ធិជួលអចិន្ត្រៃយ៍ និង សិទ្ធិផលុបភោគ ជាអាទិ៍

ជាគោលការណ៍ ការអនុវត្តដោយបង្ខំចំពោះកម្មវត្ថុនៃសិទ្ធិជួលអចិន្ត្រៃយ៍ជាអាទិ៍ គឺមិនបំពានដល់សិទ្ធិជួលអចិន្ត្រៃយ៍ទាំងនោះទេ ហេតុនេះម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍មិនអាចដាក់បណ្តឹងតវ៉ារបស់តតិយជនបានឡើយ។ ប៉ុន្តែ ជាករណីលើកលែង ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ជាអាទិ៍អាចដាក់បណ្តឹងតវ៉ារបស់តតិយជនបាន បើសិនជាការអនុវត្តដោយបង្ខំលើកម្មវត្ថុនៃសិទ្ធិជួលអចិន្ត្រៃយ៍ជាដើម ដោយផ្អែកតាមលិខិត អនុវត្តចំពោះអ្នកដទៃ ធ្វើឱ្យបំពានដល់សិទ្ធិជួលអចិន្ត្រៃយ៍ទាំងនោះ។

ឧ. C ដែលជាម្ចាស់បំណុលរបស់កម្មសិទ្ធិករ A បានអនុវត្តដោយបង្ខំផ្អែកតាមលិខិតអនុវត្តចំពោះ A ទាមទារឱ្យប្រគល់ដី L ដែល B មានសិទ្ធិប្រើប្រាស់ និង កំពុងកាន់កាប់ជាក់ស្តែង

# ហេតុនៃការគេច

4. សិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត

ជាគោលការណ៍យើងអាចពិចារណាដូចគ្នានឹងកម្មសិទ្ធិករ។ មានន័យថា អ្នកដែលមានសិទ្ធិលើបំណុល ឬ សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត អាចដាក់បណ្ដឹងតវ៉ារបស់តតិយជនបាន ក្នុងករណីសិទ្ធិទាំងនោះត្រូវបានបំពាន ដោយសារតែការអនុវត្តដោយបង្ខំផ្អែកតាមលិខិតអនុវត្តរបស់អ្នកដទៃ។

ករណីដែលតែងកើតជាបញ្ហានៅជប៉ុន :

ប្ដី A បានបង្កើតគណនីសន្សំប្រាក់ដាក់ឈ្មោះ B ដោយមិនឱ្យ B ដឹង ហើយនៅពេលដែលប្ដី A កំពុងតែគ្រប់គ្រងគណនីនោះ C ដែលជាម្ចាស់បំណុលរបស់ B បានអនុវត្តដោយបង្ខំលើប្រាក់សន្សំនោះ។

# ហេតុនៃការគេចវេះ

5. សិទ្ធិហ៊ីប៉ូតែក និង ឯកសិទ្ធិ

ម្ចាស់សិទ្ធិហ៊ីប៉ូតែក និង ឯកសិទ្ធិមានសិទ្ធិទទួលបានការសងដោយអាទិភាពពីវត្ថុដែលជាកម្មវត្ថុ ហេតុនេះ ជាគោលការណ៍ម្ចាស់សិទ្ធិហ៊ីប៉ូតែកជាអាទិ៍មិនអាចដាក់បណ្ដឹងតវ៉ារបស់តតិយជនបានទេ ពីព្រោះសិទ្ធិហ៊ីប៉ូតែកជាអាទិ៍មិនត្រូវបានបំពានដោយការអនុវត្តដោយបង្ខំចំពោះវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិហ៊ីប៉ូតែកនោះទេ។

ប៉ុន្តែ នៅពេលដែលការអនុវត្តត្រូវបានធ្វើឡើងតែមួយផ្នែក និងបំបែកវត្ថុដែលជាកម្មវត្ថុនោះ ហើយកម្មវត្ថុនោះនៅមានតម្លៃជាប្រាតិភោគនៅពេលមិនបំបែកប៉ុណ្ណោះ។ ឧទាហរណ៍ ម្ចាស់បំណុលទូទៅបានរឹបអូសដើមឈើដែលអានុភាពនៃសិទ្ធិហ៊ីប៉ូតែកខាងលើ ករណីនេះម្ចាស់សិទ្ធិហ៊ីប៉ូតែកអាចដាក់បណ្ដឹងតវ៉ារបស់តតិយជន និងដកចេញការអនុវត្តលើដើមឈើនោះបាន ដោយសារតែម្ចាស់សិទ្ធិហ៊ីប៉ូតែកមិនមានករណីយកិច្ចទទួលយកការធ្លាក់តម្លៃលើវត្ថុដែលជាកម្មវត្ថុប្រាតិភោគទេ។

# ហេតុនៃការតទ៉ា

6. សិទ្ធិឃាត់ទុក

ករណីកម្មវត្ថុគឺជាអចលនវត្ថុ ជាគោលការណ៍ ការអនុវត្តដោយបង្ខំមិនធ្វើឱ្យបំពានសិទ្ធិឃាត់ទុកទេ ហេតុនេះ ម្ចាស់សិទ្ធិឃាត់ទុកមិនអាចដាក់បណ្តឹងតវ៉ារបស់តតិយជនបានទេ។

ប៉ុន្តែ ម្ចាស់សិទ្ធិឃាត់ទុកអាចដាក់បណ្តឹងតវ៉ារបស់តតិយជនបាននៅក្នុងករណីការអនុវត្តដោយបង្ខំទាមទារឱ្យប្រគល់ ឬ ករណីរឹបអូសលើចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិឃាត់ទុកដោយគ្មានការយល់ព្រមពីម្ចាស់សិទ្ធិឃាត់ទុកបាន (CCP 386.I, 385.I) ។

# ហេតុនៃការគេហ៍

7. ប្រាតិភោគដោយអនុប្បទាន

នៅក្នុងប្រាតិភោគដោយអនុប្បទាន កម្មសិទ្ធិត្រូវផ្ទេរទៅឱ្យម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន (CC 888.I) ហេតុនេះម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានអាចដាក់បណ្តឹងតវ៉ារបស់តតិយជនបានក្នុងករណីម្ចាស់បំណុលរបស់អ្នកបង្កើតបានអនុវត្តដោយបង្ខំលើវត្ថុដែលជាកម្មវត្ថុ។

# ឧទាហរណ៍នៃសេចក្តីសម្រេចបញ្ចប់

មិនអនុញ្ញាតឱ្យអនុវត្តដោយបង្ខំលើវត្ថុដូចមានក្នុងបញ្ជីសារពើភណ្ឌស្តីពីវត្ថុចុះថ្ងៃទី ○ ខែ ○ ឆ្នាំ ○ តាមសេចក្តីចម្លងយថាភូតនៃសាលក្រមដែលបានផ្តល់រូបមន្តអនុវត្តក្នុងរឿងក្តី【ឈ្មោះតុលាការ លេខរឿងក្តី និង ឈ្មោះរឿងក្តី】របស់ចុងចម្លើយ 【ឈ្មោះកូនបំណុល】

# អាជ្ញាអស់ជំនុំ

បណ្តឹងតវ៉ារបស់តតិយជានីតិវិធីនៃបណ្តឹង ហេតុនេះអានុភាពនៃអាជ្ញាអស់ជំនុំកើតមានចំពោះអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិតវ៉ា (CCP 194)។

⇒ នៅក្នុងករណីដែលបណ្តឹងតវ៉ារបស់តតិយជនត្រូវបានច្រានចោលដើមចោទមិនអាចទាមទារឱ្យសងនូវសេចក្តីចម្រើនឥតហេតុដោយមូលហេតុការអនុវត្តនោះខុសច្បាប់ ឬមិនត្រឹមត្រូវ និងមិនអាចទាមទារសំណងការខូចខាតដោយផ្អែកលើអំពើអនិត្យានុកូលទេ។

យោង. សេចក្តីសម្រេចក្នុងសំអាងហេតុមិនកើតមានអានុភាពអាជ្ញាអស់ជំនុំនោះទេ (CCP 194.III) ហេតុនេះ អានុភាពនៃអាជ្ញាអស់ជំនុំលើបណ្តឹងតវ៉ារបស់តតិយជនមិនកើតមានចំពោះអត្ថិភាព ឬ នត្ថិភាពនៃ「សិទ្ធិដែលអាចរាំងស្ទះការធ្វើអនុប្បទាន ឬ ប្រគល់កម្មវត្ថុ」នោះទេ។ ដូចនេះ ភាគីត្រូវធ្វើបណ្តឹងផ្សេង ប្រសិនបើចង់ធ្វើឱ្យសិទ្ធិនោះស្ថាពរ។

# នីតិវិធីក្រោយចេញសាលក្រម

ទោះបីជាមានសាលក្រមទទួលស្គាល់ការតវ៉ារបស់តតិយជនក៏ដោយ ក៏ការអនុវត្តដោយបង្ខំមិនត្រូវបានផ្អាក (លុបចោល) ដោយឯកឯងនោះទេ។ យើងត្រូវដាក់សេចក្ដីចម្លងយថាភូតនៃសាលក្រមទៅតុលាការអនុវត្ត ឬ អាជ្ញាសាលា (CCP 370.I.b) ដើម្បីផ្អាកការអនុវត្ត (លុបចោល)។

# នីតិវិធីក្រោយចេញសាលក្រម

នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីមិនមានបញ្ញត្តថាត្រូវ ឬ មិនត្រូវរង់ចាំការចូលជាស្ថាពរនៃសាលក្រមតវ៉ារបស់តតិយជន ដើម្បីផ្អាកការអនុវត្តដោយបង្ខំនោះទេ (លុបចោល)។

ប៉ុន្តែ ខ្ញុំយល់ថាសេចក្ដីសម្រេចនោះគួរតែចូលជាស្ថាពរសិន ដើម្បីក្លាយជាលិខិតដែលមានកំណត់ក្នុងក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា ៣៧០ កថាខណ្ឌទី ១ ចំណុច ខ ដោយផ្អែកតាមហេតុផលខាងក្រោម៖

- ក្នុងករណីដើមចោទឈ្នះក្ដីក្នុងការតវ៉ារបស់តតិយជន តុលាការអាចសម្រេចសេចក្ដីអំពីការតវ៉ារបស់តតិយជនជាមួយនឹងការសម្រេចសេចក្ដីអំពីការផ្អាកការអនុវត្ត ឬ ការផ្អាក + ការលុបចោលការអនុវត្តបាន (CCP 368)។
- 「អានុភាពអនុវត្ត」 នៃសាលក្រមកើតឡើងពេលចូលជាស្ថាពរ (CCP 195)
- ប្រសិនបើអាចលុបចោលការអនុវត្តដោយបង្ខំនៅក្នុងស្ថានភាពមុនពេលស្ថាពរបាន ម្ចាស់បំណុលនឹងទទួលការខូចខាតយ៉ាងខ្លាំង នៅពេលដែលលទ្ធផលប្រែប្រួលនៅតុលាការជាន់ខ្ពស់។

# ការសះជា

- បណ្តឹងតវ៉ារបស់គតិយជនជាបណ្តឹងធម្មតា ហេតុនេះការសះជាក៏អាចធ្វើបានដែរ។
- ជាធម្មតា យើងមិនមែនសះជាអំពីខ្លឹមសារនៃសិទ្ធិតវ៉ានោះទេ (「មិនអនុញ្ញាតឱ្យអនុវត្តដោយបង្ខំ」ជាអាទិ៍) ប៉ុន្តែយើងបញ្ចូលខ្លឹមសារ និង អត្ថិភាពឬនត្ថិភាពនៃសិទ្ធិតាមច្បាប់សារធាតុដែលជាមូលហេតុនៃការតវ៉ា (ការបញ្ជាក់អំពីកម្មសិទ្ធិ ជាអាទិ៍) ទៅក្នុងចំណុចនៃការសះជា។ លើសពីនេះ យើងក៏មានបញ្ចូលចំណុចដូចជា「មិនអនុវត្តដោយបង្ខំ」ផងដែរ (ត្រូវនឹងCCP370.I.f)។ នៅក្នុងករណីណាក៏ដោយ យើងត្រូវធ្វើយ៉ាងណាមិនឱ្យនៅសល់សិទ្ធិតវ៉ាតាមនីតិវិធីច្បាប់ ហើយជាទូទៅ យើងកំណត់ទុកជាមុនអំពីការព្រមព្រៀងបញ្ចប់បណ្តឹង ឬ ព្រមព្រៀងដកបណ្តឹងតវ៉ានោះ ។

# ការផ្អាកការអនុវត្ត

ទោះបីជាដាក់បណ្ដឹងតវ៉ារបស់តតិយជនក៏ដោយ ក៏ការអនុវត្តដោយបង្ខំមិនផ្អាកដោយឯកឯងដែរ។

⇒ដើម្បីផ្អាកការអនុវត្តដោយបង្ខំ យើងត្រូវដាក់ពាក្យសុំផ្អាកការអនុវត្តទៅតុលាការដែលបានទទួលពាក្យបណ្ដឹង (CCP 367)។

# ការផ្អាកការអនុវត្ត

## លំហូរនៃការផ្អាក

បណ្តឹងតវ៉ារបស់តតិយជន

↓

ពាក្យសុំផ្អាកការអនុវត្ត

↓

វិនិច្ឆ័យការផ្អាកការអនុវត្ត

↓

ដីកាកំណត់តម្លៃប្រាតិភោគ និង ការដាក់ប្រាតិភោគ

↓

ដីកាសម្រេចផ្អាកការអនុវត្ត

↓

ដាក់សេចក្តីចម្លងយថាភូតនៃដីកាសម្រេចទៅតុលាការ

↓

ការអនុវត្តដោយបង្ខំត្រូវបានផ្អាកមួយរយៈ

# ការផ្អាកការអនុវត្ត

ពាក្យសុំផ្អាកការអនុវត្ត

1. សមត្ថកិច្ច

តុលាការដែលទទួលពាក្យបណ្តឹងតវ៉ារបស់តតិយជន (CCP 367.I)

2. ខ្លឹមសារនៃពាក្យសុំ

- ផ្អាកការអនុវត្តដោយបង្ខំមួយរយៈ (CCP 367.I)
- ផ្អាកការអនុវត្តដោយបង្ខំមួយរយៈ + លុបចោលការចាត់ចែងការអនុវត្តដែលបានធ្វើរួចហើយ (CCP 367.II)

※ ការផ្អាកការអនុវត្តមួយរយៈគឺជាអំឡុងពេលដែលត្រូវសម្រេចសេចក្តីលុបចោល ផ្លាស់ប្តូរ ឬ ទទួលស្គាល់លើសាលក្រមចុងក្រោយ នៅក្នុងដីកាសម្រេចផ្អាកការអនុវត្តដោយបង្ខំមួយរយៈ (CCP 367.I, 368)។

# ការផ្អាកការអនុវត្ត

លក្ខខណ្ឌនៃការផ្អាកការអនុវត្ត (CCP 367.I)

① មានការដាក់បណ្ដឹងតវ៉ារបស់តតិយជន

② មានការបញ្ជាក់ដំបូងអំពីហេតុនៃការតវ៉ាដែលបានអះអាង

→ គឺជា ការបញ្ជាក់ដំបូងអំពីអត្ថិភាពនៃ「កម្មសិទ្ធិ ឬ សិទ្ធិផ្សេងទៀតដែលអាចរាំងស្ទះការធ្វើអនុប្បទាន ឬ ការប្រគល់វត្ថុដែលជាកម្មវត្ថុ」 នៃការអនុវត្តដោយបង្ខំ(CCP 365.I)។

# ការផ្អាកការអនុវត្ត

វិធីវិនិច្ឆ័យ

ជាទូទៅការវិនិច្ឆ័យធ្វើឡើងទៅលើតែឯកសារ ដោយមិនមានការបើកការទាញហេតុផលផ្ទាល់មាត់ ឬ សាកសួរភាគីម្ខាងទៀតទេ។

∵① មានភាពប្រញាប់។

② នៅក្នុងសាលក្រមចុងក្រោយ តុលាការមានឆន្ទានុសិទ្ធិសម្រេចអំពីការទទួលស្គាល់ ឬ មិនទទួលស្គាល់សេចក្តីសម្រេចផ្អាកការអនុវត្តជាអាទិ៍ (CCP 368) ហេតុនេះទោះបីជាមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ ឬ សាកសួរភាគីម្ខាងទៀតក៏ដោយក៏តុលាការអាចស្តាប់យោបល់របស់ភាគីម្ខាងទៀតបាននៅក្នុងបណ្តឹងអង្គសេចក្តីដែរ។

# ការផ្អាកការអនុវត្ត

អំពីប្រាតិភោគ

1. ការផ្អាកការអនុវត្តដោយបង្ខំមួយរយៈ

តុលាការអាចបង្គាប់ឱ្យដាក់ ឬ មិនដាក់ប្រាតិភោគបាន (CCP 367.I)។ ប្រសិនបើត្រូវដាក់ប្រាតិភោគក៏ដោយ ក៏ប្រាតិភោគនោះធ្វើឡើងសម្រាប់តែការខូចខាតដែលកើតមានចំពោះម្ចាស់បំណុលដោយសារការយឺតយ៉ាវនៃការអនុវត្តនោះទេ ហេតុនេះតម្លៃប្រាតិភោគជាទូទៅមិនមានចំនួនច្រើនខ្លាំងទេ។

2. ការផ្អាកការអនុវត្តដោយបង្ខំមួយរយៈ + លុបចោលការចាត់ចែងការអនុវត្តដែលបានធ្វើរួចហើយ

តុលាការត្រូវតែបង្គាប់ឱ្យដាក់ប្រាតិភោគ (CCP 367.II)។ តម្លៃប្រាតិភោគគឺតម្រូវឱ្យគ្រប់ចំនួនការពារផលប្រយោជន៍ទាំងអស់ដែលម្ចាស់បំណុលមានលើការអនុវត្តចាត់ចែងដែលត្រូវបានលុបចោល ហេតុនេះ តម្លៃប្រាតិភោគមានចំនួនច្រើនខ្លាំង។

# ការផ្អាកការអនុវត្ត

## អំពីប្រាតិភោគ

- ក្នុងករណីតុលាការបង្គាប់ឱ្យដាក់ប្រាតិភោគ ដំបូងតុលាការនឹងចេញដីកាសម្រេចអំពីតម្លៃប្រាតិភោគ (ឬ វត្ថុដែលជាប្រាតិភោគ) និង អំឡុងពេលដាក់ប្រាតិភោគ។ តុលាការចេញដីកាផ្អាកការអនុវត្ត ក្រោយពីបញ្ជាក់ថាបានដាក់ប្រាតិភោគ។
- វិធីដាក់ប្រាតិភោគគឺតម្កល់ ឬផ្ញើប្រាក់ជាអាទ៏នៅទីកន្លែងតម្កល់ (តុលាការ)។ (CCP 71.I)
- ក្នុងករណីដែលមិនបានដាក់ប្រាតិភោគក្នុងអំឡុងពេលកំណត់ទេ តុលាការនឹងលើកចោលពាក្យសុំ។

# ការផ្អាកការអនុវត្ត

ខ្លឹមសារនៃដីកាសម្រេច

ករណីតុលាការបានចេញដីកាសម្រេចបង្គាប់ឱ្យដាក់ប្រាតិភោគ តុលាការនឹងចេញដីកាសម្រេចអំពីការផ្អាកការអនុវត្ត ក្រោយពេលបញ្ជាក់អំពីការដាក់ប្រាតិភោគ។

- តុលាការអាចបង្គាប់ឱ្យដាក់ ឬ មិនដាក់ប្រាតិភោគសម្រាប់ការផ្អាកការអនុវត្តដោយបង្ខំជាបណ្ដោះអាសន្នបាន (CCP 367.I)។
- តុលាការត្រូវបង្គាប់ឱ្យដាក់ប្រាតិភោគសម្រាប់ការផ្អាកការអនុវត្តដោយបង្ខំជាបណ្ដោះអាសន្ន + លុបចោលការចាត់ចែងការអនុវត្តដែលបានធ្វើរួចហើយ (CCP 367.II)។

※ តុលាការមានឆន្ទានុសិទ្ធិក្នុងការចេញដីកាសម្រេចណាមួយ។ ប៉ុន្តែ តុលាការមិនអាចចេញដីកាសម្រេចលុបចោលការអនុវត្តចំពោះពាក្យសុំដែលទាមទារត្រឹមតែផ្អាកការអនុវត្តនោះទេ។

# ការផ្អាកការអនុវត្ត

ឧទាហរណ៍នៃដីកាសម្រេច

## ដីកាសម្រេចផ្អាកការអនុវត្តដោយបង្ខំ

អ្នកដាក់ពាក្យសុំបានដាក់បណ្ដឹងតវ៉ារបស់តតិយជនចំពោះការអនុវត្តដោយបង្ខំផ្អែកតាមសេចក្ដីចម្លងយថាភូតនៃសាលក្រមដែលមានអានុភាពអនុវត្តចំពោះ 【 រឿងក្ដីឈ្មោះ.... រឿងក្ដីលេខ.... និងតុលាការឈ្មោះ.... 】ពីភាគីម្ខាងទៀត【កូនបំណុលឈ្មោះ....】និងបានដាក់ពាក្យសុំផ្អាកការអនុវត្តនោះ។ តុលាការទទួលស្គាល់ថាពាក្យសុំនោះមានមូលហេតុសមរម្យ ហើយអ្នកដាក់ពាក្យសុំបានដាក់តម្កល់ជាប្រាក់ប្រាតិភោគចំនួន ○○

ហេតុនេះ តុលាការសម្រេចដូចខាងក្រោម៖

## សេចក្ដីសម្រេចបញ្ជាប់

ផ្អាកការអនុវត្តដោយបង្ខំមួយរយៈលើវត្ថុដូចមានក្នុងបញ្ជីសារពើភណ្ឌស្ដីពីវត្ថុចុះថ្ងៃទី ○ ខែ ○ ឆ្នាំ ○【សង្ខេប】ផ្អែកតាមការអនុវត្តខាងលើ រហូតដល់តុលាការនៃបណ្ដឹងអង្គសេចក្ដី ធ្វើការសម្រេចអំពី ការលុបចោល ឬផ្លាស់ប្ដូរ ឬទទួលស្គាល់ការអនុវត្ត។

# ការផ្អាកការអនុវត្ត

ក្រោយចេញដីកាសម្រេច

- ការអនុវត្តដោយបង្ខំនឹងត្រូវបានផ្អាក (ត្រូវបានលុបចោល) បើសិនជាភាគីបានដាក់សេចក្តីចម្លងយថាភូតនៃដីកាសម្រេចផ្អាកការអនុវត្ត (លុបចោល) ទៅតុលាការអនុវត្ត ឬអាជ្ញាសាលា។ (CCP 370.II.a, I.g)

ការធ្វើឧបាស្រ័យ

- ភាគីមិនអាចធ្វើឧបាស្រ័យបានទេ ដោយសារតែមិនមានបញ្ញត្តិទទួលស្គាល់ការប្តឹងជំទាស់ចំពោះដីកាសម្រេចផ្អាកការអនុវត្ត។ ប៉ុន្តែភាគីអាចដាក់ពាក្យសុំតវ៉ាចំពោះការអនុវត្តបាន (CCP 344) ក្នុងករណីដែលការអនុវត្តដោយបង្ខំត្រូវបានផ្អាក ដោយផ្អែកលើសេចក្តីចម្លងយថាភូតនៃដីកាសម្រេចនេះ។

# ការផ្អាកការអនុវត្ត

ឋានៈរបស់ដីកាសម្រេចផ្អាកការអនុវត្តនៅក្នុងសាលក្រមចុងក្រោយ (CCP 368)

- តុលាការអាចធ្វើការផ្អាកការអនុវត្ត ឬ ផ្អាកការអនុវត្ត + លុបចោលការចាត់ចែង នៅក្នុងសាលក្រមចុងក្រោយនៃការតវ៉ារបស់តតិយជនបាន។
- ប្រសិនបើសេចក្តីសម្រេចអំពីការផ្អាកការអនុវត្តជាដើមត្រូវបានផ្អាកហើយ តុលាការត្រូវតែសម្រេចថាលុបចោល ផ្លាស់ប្តូរ ឬ ទទួលស្គាល់នូវសេចក្តីសម្រេចទាំងនោះ។

*Thank you for listening!*